# សេចក្តីប្រកាសព័ត៌មាន

នាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ វេលាម៉ោង ៩:០០ ព្រឹក នៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ មានប្រារព្ធកិច្ចប្រជុំថ្នាក់អគ្គនាយកគយអាស៊ាន-ជប៉ុន ដោយមានកិច្ចសហការពីធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការគយពិភពលោក ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ។ សមាសភាពចូលរួមកិច្ចប្រជុំនេះមាន គណប្រតិភូជាន់ខ្ពស់តំណាងរដ្ឋបាលគយនៃប្រទេសសមាជិកអាស៊ានទាំង ១០ រដ្ឋបាលគយជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) អង្គការគយពិភពលោក (WCO) និងលេខាធិការដ្ឋានអាស៊ាន ។

នៅក្នុងពិធីបើកកិច្ចប្រជុំនេះ មានវត្តមានដ៏ខ្ពង់ខ្ពស់ជាអធិបតីរបស់**ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការថ្លែងសុន្ទរកថាបើកដោយ**ឯកឧត្តមបណ្ឌិត ម៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា **ឯកឧត្តម** Atsuo Shibota អគ្គនាយករដ្ឋបាលគយជប៉ុន **លោក** Kunio Senga អគ្គនាយកធនាគារអភិវឌ្ឍន៍អាស៊ីទទួលបន្ទុកតំបន់អាស៊ីអគ្នេយ៍ **លោក** Kunio Mikuriya អគ្គលេខាធិការនៃអង្គការគយពិភពលោក និង**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ។

កិច្ចប្រជុំនេះ ត្រូវបានប្រារព្ធឡើងតាមស្មារតីនៃ "ផែនការមេស្តីពីការភ្ជាប់ទំនាក់ទំនងអាស៊ាន (Master Plan on ASEAN Connectivity)" ដែលបានអនុម័តដោយថ្នាក់ដឹកនាំបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចប្រជុំកំពូលលើកទី ១៧ នៅទីក្រុងហាណូយ នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០ និងតាមគំនិតផ្តួចផ្តើមរបស់ភាគីជប៉ុនលើការពង្រឹងថែមទៀតនូវការតភ្ជាប់កម្រិតអាស៊ាន-ជប៉ុន (ASEAN-Japan Connectivity) ។ គោលបំណងចំបងនៃកិច្ចប្រជុំនេះ គឺផ្តោតលើការរិះរកយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវគោលដៅរួម នៃការបង្កើនកិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់អាស៊ីនាទសវត្សខាងមុខនេះ ។

ក្នុងដំណើរការពិភាក្សាពេញ ១ ថ្ងៃ អង្គប្រជុំបានចែករំលែកគ្នានូវទស្សនទាននៃ "**មហាវិថីទំនិញនៅអាស៊ី** Asia Cargo Highway" ដែលជាយុទ្ធសាស្ត្ររយៈពេលវែងក្នុងការសម្រួលឲ្យមានលំហូរទំនិញដោយសេរីនៅអាស៊ី ។ "**មហាវិថីទំនិញនៅអាស៊ី**" នេះអាចសម្រេចបានតាមរយៈ ÷

១. ការបង្កើតឡើងនូវប្រតិបត្តិករសេដ្ឋកិច្ចដែលបានផ្តល់សិទ្ធិ (Authorized Economic Operator - AEO) នៅក្នុងប្រទេសនីមួយៗ និងឈានទៅបង្កើតឲ្យមានការទទួលស្គាល់ទៅវិញទៅមកក្នុងកម្រិតតំបន់ ។

២. ការបង្កើតប្រព័ន្ធបញ្ជរតែមួយថ្នាក់ជាតិក្នុងប្រទេសនីមួយៗ និងការពង្រីកការតភ្ជាប់ប្រព័ន្ធនេះក្នុងចំណោមប្រទេសទាំងអស់ ។

៣. អនុវត្តកម្មវិធីកំណែទម្រង់ពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្មជាមូលដ្ឋានផ្សេងទៀត ដែលចាំបាច់ក្នុងការធ្វើទំនើបកម្មរដ្ឋបាលគយ ។

អង្គប្រជុំបានទទួលស្គាល់ថា ទស្សនៈនេះស្របគ្នាជាមួយនឹងគំនិតផ្តួចផ្តើមនៃកិច្ចសម្រួលពាណិជ្ជកម្មដទៃទៀត រាប់បញ្ចូលទាំងផែនការមេស្តីពីការភ្ជាប់ទំនាក់ទំនងអាស៊ាន និងទស្សនៈវិស័យរដ្ឋបាលគយអាស៊ានឆ្នាំ ២០១៥ ផងដែរ ។

ADB, JICA និង WCO ក៏ទទួលស្គាល់ពីសារសំខាន់នៃរបៀបវារៈរៀងខ្លួន និងគោលដៅរួម ASEAN ហើយបានបង្ហាញពីការត្រៀមរួចជាស្រេច ក្នុងការជួយកិច្ចខិតខំប្រឹងប្រែងនេះ ទាំងក្នុងក្របខណ្ឌប្រទេសនីមួយៗរៀងខ្លួន និងជាក្រុមរួមមួយ ។ កិច្ចប្រជុំនេះក៏បានបញ្ជាក់បន្ថែមដែរថា កិច្ចសហប្រតិបត្តិការអាស៊ាន ជាមួយ ADB, JICA, និង WCO នឹងក្លាយជាសរសរស្តម្ភមួយនៃគំនិតផ្តួចផ្តើមលើការសម្រួលពាណិជ្ជកម្ម ។

ក្រោយពីបានចែករំលែកមតិយោបល់ និងការជជែកពិភាក្សាលើសកម្មភាពដើម្បីជម្រុញបន្ថែមការសម្រួលពាណិជ្ជកម្មក្នុងអាស៊ី ព្រមជាមួយនឹងការផ្ទៀងផ្ទាត់ឡើងវិញនូវបេសកកម្មជាប្រពៃណីនៃរដ្ឋបាលគយដូចជា ការប្រមូលចំណូល និងការការពារសន្តិសុខសង្គម អង្គប្រជុំបានយល់ស្របលើអត្តិភាព និងសកម្មភាពដូចខាងក្រោម÷

- **ទំនើបកម្មគយ ÷** ចាត់វិធានការច្បាស់លាស់ក្នុងរយៈពេល ៥ ឆ្នាំ ខាងមុខនេះ ដើម្បីធ្វើការសម្រួលសុខដុមនីយកម្ម បង្កើនល្បឿន និង បង្កើនតម្លាភាព និងភាពអាចព្យាករណ៍បាន នៅក្នុងនីតិវិធី និងការអនុវត្តពាក់ព័ន្ធនឹងវិស័យគយ ឆ្ពោះទៅការសម្រេចគោលបំណងរួម ។
- **ការគ្រប់គ្រងហានិភ័យ ÷** ព្រមព្រៀងនឹងសម្រេចឲ្យបាននូវការអនុវត្តពេញលេញនៃប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយសមត្ថភាពគ្រប់គ្រាន់ នៅឆ្នាំ ២០១៣ ដែលនឹងជួយជម្រុញដល់ការបង្កើតកម្មវិធី AEO ។ ដោយយល់ពីសារៈសំខាន់នៃការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការគ្រប់គ្រងហានិភ័យ អង្គប្រជុំក៏បានស្រុះស្រួលគ្នាក្នុងការស្វែងរក ការបង្កើតទិន្នន័យបណ្តាញប្រតិបត្តិការគយថ្នាក់ជាតិរបស់អង្គការគយពិភពលោក WCO National Customs Enforcement Network (NCEN) ក្នុងប្រទេសដែលមានចំណាប់អារម្មណ៍ ។
- **កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចដែលបានផ្តល់សិទ្ធិ (Authorized Economic Operator - AEO) និងការទទួលស្គាល់គ្នាទៅវិញទៅមកក្នុងកម្រិតតំបន់ Mutual Recognition Arrangements (MRAs) ÷** ការអនុវត្តនូវកម្មវិធី AEO គឺជាដំណោះស្រាយផ្នែកស្ថាប័នមួយសម្រាប់ការលំបាកនៃការផ្ទៀងផ្ទាត់ឡើងវិញលើការសម្រួលពាណិជ្ជកម្ម និងសន្តិសុខពាណិជ្ជកម្ម ។ កម្មវិធី AEO រំពឹងថានឹងត្រូវបានបង្កើតនៅក្នុងប្រទេសអាស៊ាន ៦ នៅឆ្នាំ ២០១៤ និងនៅក្នុងប្រទេសអាស៊ាន ៤ នៅឆ្នាំ ២០១៨ ប្រកបដោយលក្ខណៈស្របទៅនឹង សេចក្តីណែនាំស្តីពី AEO ក្នុងបទដ្ឋានក្របខណ្ឌ WCO SAFE ។ ការពង្រីកបន្ថែមបណ្តាញនៃការទទួលស្គាល់គ្នាទៅវិញទៅមកក្នុងកម្រិតតំបន់ សំដៅដល់ការសម្រេចនូវមហាវិថីទំនិញនៅអាស៊ីគឺជាមហិច្ឆតារយៈពេលវែង។
- **ប្រព័ន្ធបញ្ជរតែមួយថ្នាក់ជាតិ National Single Windows (NSWs):** បានទទួលស្គាល់នូវសារសំខាន់នៃការកសាងប្រព័ន្ធបញ្ជរតែមួយថ្នាក់ជាតិ ជាមធ្យោបាយដើម្បីកាត់ន្ថយការចំណាយ និងពេលវេលាក្នុងការបញ្ចេញទំនិញពីគយ និងដើម្បីធ្វើឲ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ ។ ថ្នាក់ដឹកនាំ ប្រទេសអាស៊ាន បានបញ្ជាក់ជាថ្មីនូវឆន្ទៈក្នុងការអនុវត្តឲ្យបានពេញលេញនូវប្រព័ន្ធបញ្ជរតែមួយថ្នាក់ជាតិរៀងខ្លួន នៅឆ្នាំ ២០០៨ (ក្នុងប្រទេសអាស៊ាន ៦) និង ២០១២ (ក្នុងប្រទេសអាស៊ាន ៤) ក្នុងគោលបំណងបង្កើតប្រព័ន្ធបញ្ជរតែមួយថ្នាក់អាស៊ាន នៅឆ្នាំ ២០១៥ ។
- **ប្រព័ន្ធបញ្ជរតែមួយដែលអាចប្រើប្រាស់បានជាអន្តរជាតិ ÷** អង្គប្រជុំបានព្រមព្រៀងលើការសិក្សា និងស្វែងរកមធ្យោបាយដើម្បីគាំទ្រការដោះដូរតាមបែបអេឡិចត្រូនិក នូវឯកសារពាណិជ្ជកម្មពាក់ព័ន្ធនឹងជំនួញ ដោយមានយល់ព្រមពីអ្នកនាំចូល និងអ្នកនាំចេញ ដែលជាគំនិតផ្តួចផ្តើមរបស់វិស័យជំនួញ ។ កិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានរំពឹងថានឹងចូលរួមចំណែកក្នុងការសម្រេចឲ្យបាននូវ ប្រព័ន្ធបញ្ជរតែមួយថ្នាក់អាស៊ាន នៅឆ្នាំ ២០១៥ និងជួយជម្រុញការតភ្ជាប់ប្រព័ន្ធបញ្ជរតែមួយរវាងប្រទេសអាស៊ាន ជាមួយប្រព័ន្ធបញ្ជរតែមួយរបស់ប្រទេសជប៉ុន ។

- **ការសិក្សាពីរយៈពេលបំពេញបែបបទបញ្ចេញទំនិញពីគយ (Time Release Studies) ៖** អង្គប្រជុំបានអនុម័តលើគំនិតនៃការអនុវត្តការសិក្សាពីរយៈពេលបំពេញបែបបទបញ្ចេញទំនិញពីគយ ក្នុងកិច្ចសហប្រតិបត្តិការជាមួយ ADB និង WCO ក្នុងឆ្នាំ ២០១២ និង ២០១៥ ដោយឈរលើមូលដ្ឋាន មគ្គុទេសក៍ការសិក្សាពីរយៈពេលបំពេញបែបបទបញ្ចេញទំនិញពីគយរបស់អង្គការ WCO ដែលបានកែសម្រួល ។

អង្គប្រជុំបានសង្កត់បន្ថែមលើសារសំខាន់នៃគម្រោងសហប្រតិបត្តិការជាមួយនឹងស្ថាប័នជាដៃគូ ដូចជា ADB JICA WCO ដើម្បីបង្កើនសមត្ថភាពនៃការសម្រួលពាណិជ្ជកម្ម ។ ប្រទេសជប៉ុននឹងចេញវិភាគទានរហូតដល់ទៅ ២៥លានដុល្លាសហរដ្ឋអាមេរិកក្នុងរយៈពេល ៥ ឆ្នាំ សម្រាប់គម្រោង ADB លើការសម្រួលពាណិជ្ជកម្ម ដែលនឹងផ្តោតលើប្រទេសអាស៊ានសម្រាប់កំឡុងពេលបច្ចុប្បន្ននេះ ។ ប្រតិភូប្រទេសអាស៊ានទាំងអស់ បានស្វាគមន៍ចំពោះការចូលរួមវិភាគទានរបស់ប្រទេសជប៉ុន និងការប្តេជ្ញារបស់ ADB JICA WCO និងប្រទេសអាស៊ានមួយចំនួន ក្នុងការគាំទ្រដល់គម្រោងសហប្រតិបត្តិការនេះ ។

ប្រតិភូទាំងអស់ បានបញ្ជាក់បន្ថែមពីតួនាទីសំខាន់នៃការខិតខំប្រឹងប្រែងលើការងារសម្រួលពាណិជ្ជកម្មរបស់ប្រទេសរៀងខ្លួន ក្នុងការជម្រុញសមាហរណកម្មក្នុងតំបន់ និង ការរីកចម្រើនផ្នែកសេដ្ឋកិច្ច ។ លទ្ធផលនៃការពិភាក្សាក្នុងថ្ងៃនេះ នឹងត្រូវបានរាយការណ៍ជូនរដ្ឋមន្ត្រីហិរញ្ញវត្ថុរៀងខ្លួន មុននឹងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីដែលនឹងប្រព្រឹត្តទៅ នៅទីក្រុង **ហា ណូយ** នៅសប្តាហ៍ក្រោយនេះ និងនៅក្នុងកិច្ចប្រជុំកំពូល អាស៊ាន-ជប៉ុន លើកទី ១៤ ដែលនឹងប្រព្រឹត្តទៅនៅប្រទេស **ឥណ្ឌូនេស៊ី** នៅក្នុងឆ្នាំនេះ ។ អង្គប្រជុំ ក៏បានអះអាងបន្ថែមទៀតអំពី សារសំខាន់នៃការបន្តការពិគ្រោះយោបល់ខាងនយោបាយ ដោយឈរលើមូលដ្ឋានជាសមភាគី ព្រមទាំងបានស្នើឱ្យមានការចូលរួមពីសំណាក់ ADB JICA និង WCO ក្នុងដំណើរការនៃការពិគ្រោះយោបល់គ្នានេះ ។ នៅឆ្នាំក្រោយ នឹងមានការអនុវត្តការវាយតម្លៃលើលទ្ធផលដែលសម្រេចបាន កំណត់នូវបញ្ហាជាអាទិភាពបន្ទាប់ និងបង្កើតផែនការការងារដើម្បីដោះស្រាយបញ្ហាទាំងនោះ ។

**Press Release: ASEAN-Japan Directors-General/Commissioners Meeting on Trade Facilitation, Le Royal Hotel, Phnom Penh, Cambodia, April 29th, 2011**

The Directors-General/Commissioners of the Customs administrations of the ASEAN Member States and Japan Customs and Tariff Bureau held a meeting in Phnom Penh, Cambodia on April 28-29, 2011, in cooperation with the Asian Development Bank (ADB). In the meeting, there were delegation from the customs administrations of all ASEAN members, Japan Customs and Tariff Bureau, the ASEAN Secretariat, the Japan International Cooperation Agency (JICA) and the World Customs Organization (WCO).

The meeting titled “ASEAN-Japan Directors-General/Commissioners Meeting on Trade Facilitation” was opened by **H.E. Dr. Pen Siman**, Delegate of the Royal Government in charge of the General Department of Customs and Excise of Cambodia, **H.E. Mr. Atsuo Shibota**, Director General of the Japan Customs and Tariff Bureau, Mr. Kunio Senga, Director General of the ADB, Southeast Asia Department, **Mr. Kunio Mikuriya**, Secretary General of the WCO, and **H.E. Keat Chhon**, Deputy Prime Minister, Minister of Economy and Finance of the Kingdom of Cambodia.

The meeting was organized in the spirit of the Master Plan on ASEAN Connectivity, endorsed by ASEAN leaders at the 17th Summit in Ha Noi on October 28, 2010, and the Japan’s new initiative on further enhancing ASEAN-Japan institutional connectivity. The purpose of the meeting was to discuss on how to achieve their common goal of further trade facilitation in Asia in the next decade.

Following the agenda, the meeting discussed and shared the concept of an “Asia Cargo Highway” (ACH) as their long-term direction to create seamless flows of goods in Asia. The ACH will be achieved through (i) *development of an Authorized Economic Operator (AEO) program in each country, and conclusion of mutual recognition arrangements (MRAs) of the AEO programs*, (ii) *establishment of a national single window (NSW) system in each country, and expansion of international interoperability between the systems*, and (iii) *other basic trade facilitation reforms that are necessary for modern customs administration*. The meeting recognized that this concept is consistent with their other trade facilitation initiatives, including the Master Plan on ASEAN Connectivity and the ASEAN Customs Vision 2015, and, therefore, agreed on the need to undertake efforts to work towards the ACH.

The ADB, JICA and the WCO also recognized the complementarities between their respective agendas and the ASEAN common goals, and expressed their readiness to assist these endeavors, both individually in their respective realms of expertise and collectively as a team. The meeting reaffirmed that ASEAN’s cooperation with the ADB, JICA and the WCO will be an important pillar of their trade facilitation initiatives.

After sharing views and discussion on activities to further facilitate trade in Asia, while reconciling the traditional missions of customs administrations, such as revenue collection and the protection of society, the meeting agreed on the following priorities and actions:

- ***Customs Modernization:*** They will take concrete measures over the coming 5 years to simplify, harmonize, expedite and improve transparency and predictability in customs-related procedures and practices toward the realization of their common goals.
- ***Risk Management:*** They agreed to achieve the full implementation of efficient risk management systems by 2013, which will facilitate the establishment of the AEO programs. Recognizing that the creation of database for risk management is of vital importance, they also agreed to seek the introduction of the WCO National Customs Enforcement Network (NCEN) database in interested countries.
- ***The Authorized Economic Operator (AEO) program and mutual recognition arrangements (MRAs):*** Implementation of the AEO program is an institutional solution to the challenge of reconciling trade facilitation and trade security. They expected that the AEO programs would have been established in ASEAN 6 countries and ASEAN 4 countries by 2014 and 2018, respectively, in a manner that is consistent with the AEO guidelines in the WCO SAFE Framework of Standards. Their long-term ambition is to further expand their network of MRAs toward the realization of the ACH.
- ***National Single Windows (NSWs):*** They recognize the importance of building NSWs as a means to reduce processing costs and clearance time and to improve the trade and investment environment. The ASEAN leaders reaffirmed their commitment to fully implement the respective NSWs by 2008 (in ASEAN 6 countries) and 2012 (in ASEAN 4 countries), with an aim to establish the ASEAN Single Window (ASW) by 2015.
- ***International Interoperability between NSWs:*** The meeting agreed to study and explore ways to support electronic exchange of trade-related commercial documents with the consent of exporters and importers involved, which is the business sector's initiative. They expected that these efforts will contribute to the realization of the ASW by 2015 and will improve the international interoperability between the ASW and Japan's NSW.
- ***Time Release Studies (TRS):*** All ASEAN countries endorsed the idea of conducting TRSs in 2012 and 2015 based on the revised WCO TRS Guide in cooperation with the ADB and the WCO.

The meeting stressed the importance of cooperative projects with their partner institutions, namely the ADB, JICA and the WCO to build up trade facilitation capacity. Japan will contribute up to US$25 million over the 5 years for ADB projects on trade facilitation, which will focus on ASEAN for the time being. All ASEAN customs delegates welcomed Japan's contribution and the commitment of the ADB, JICA, the WCO and some of their countries to support such cooperative projects.

All the delegates reconfirmed the significant role of their trade facilitation efforts in promoting regional integration and economic growth. They will report the results of today's discussion to their respective finance ministers before the ministerial meetings to be held in Ha Noi next week and at the 14th ASEAN-Japan Summit to be held in Indonesia later this year. They strongly reaffirmed the importance of continuing their policy consultations based on their equal partnerships. The meeting called for the participation of the ADB, JICA and the WCO in this consultation process. Next year, they will conduct stock-taking on the progress made by then, identify their next priority issues and develop a work plan to address them.